# ការសំភាសន៍របស់អ្នកមីង ដុល ស្រី

ក៖ អ្នកដែរសំភាសន៍គេ ជាងស៊ីអ៊ារខ៖ អ្នកដែរអោយគេសំភាសន៍ ដុល ស្រី

ក៖ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយ
នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន
សំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង
ចឹងតើមីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខ៖ អោយតីឡូ
ខាងណុងគេមានអំណោយទានអីច្រើនចឹងគេបានដាក់អោយខ្មែរចឹងហាស

ក៖ បាទខ្ញុំមិនដឹងដែរនឹងមួយនឹង?

ខ៖ ចេះតែថាម៉ង់

ក៖ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ
ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍មីងមួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី19 ខែ2 ឆ្នាំ2018
ហើយការសំភាសន៍មួយនឹងធ្វើនៅភូមិបាលាំងថ្មី ចុះយ?

ខ៖ នៅឃុំល្អាង ស្រុកកំពង់សៀម

ក៖ ឃុំល្អាង ស្រុកកំពង់សៀម ខេត្តកំពង់ចាមនឹង
ចឹងសំរាប់មីងមានឈ្មោះពេញនឹងឈ្មោះអីគេដែរមីង?

ខ៖ ខ្ញុំឈ្មោះ ដុល ស្រី

កៈ ចុះមានឈ្មោះហៅក្រៅដែរទេមីង?

ខៈ ហៅក្រៅនឹងឈ្មោះទរៗៗនឹង

កៈ ចុះកាលពីក្មេងនឹងមាននរណាគេហៅឈ្មោះមីងអីផ្សេងទៀតទេ?

ខៈ អត់ទេមានតែប៉ុណ្ណឹងឯងនឹង

កៈ ចុះសព្វថ្ងៃនឹងមីងមានអាយុប៉ុន្មានដែរមីង?

ខៈ ខ្ញុំអាយុ43ឆ្នាំ

កៈ មីងកើតនៅថ្ងៃខែឆ្នាំណាមិងមានចងចាំទេ?

ខៈ ខ្ញុំកើតនៅឆ្នាំ1973

កៈ ចុះថ្ងៃខែមីងមានចងចាំទេ ដូចថាថ្ងៃណា ខែណាចឹងហាសមីង?

ខៈ ម៉ែថានៅខែ6 ថ្ងៃទី9ម៉េចទេនឹង

កៈ ថ្ងៃទី9 ខែ6 ចុះឆ្នាំច័ន្ទគតិមីងឆ្នាំអីគេមីងមានចងចាំទេ លក្ខណៈដូចឆ្នាំ ជូត ឆ្លូវ ខាល ថោះអីហាស?

ខៈ ខ្ញុំឆ្នាំថោះនឹង

កៈ ចឹងមីងឆ្នាំថោះណាមីង ចុះមីងកើតនៅទីកន្លែងណាដែរមីង?

ខៈ កើតនៅនឹង

កៈ ភូមិអី ឃុំអី ស្រុកអី ខេត្តអីដែរមីង?

ខៈ កើតនៅនឹងតែម្តងនឹង

កៈ ចឹងមីងកើតនៅនឹងហោសមីង?

ខៈ ទេម៉ែថាកើតមកពីនោះមកនឹងពីអូរដា ហើយរត់មកនឹង

កៈ ពីអូរដាហោស ប៉ុន្តែអូរដានឹងនៅភូមិអី ឃុំអីដែរមីង?

ខៈ នៅកំពង់ចាមដែរនឹង

កៈ ប៉ុន្តែភូមិអីគេដែរមីង?

ខៈ ទាល់តែម៉ែរបស់ខ្ញុំមកនឹង

កៈ អ្ហូ!ចឹងមីងមិនសូវចងចាំដែរហោសមីង?

ខៈ ខ្ញុំមានបងប្អូនច្រើនណាស់មើលប៉ុន្តែស្លាប់ងស់ខ្លះហើយនឹង

កៈ ប៉ុន្តែប៉ុន្មាននាក់ដែរទៅមីង?

ខៈ បើខាងសំបុកខ្ញុំនឹងមានខ្ញុំ មីងខេង មីងក្អុក អាម៉េង អាដុច ទាំងអស់5នាក់

កៈ អ្ហូ!ចឹងមាន5នាក់ហោស ចឹងមីងជាកូនទីប៉ុន្មានដែរមីង?

ខៈ ខ្ញុំជាកូនបងបង្អស់នឹង

កៈ មីងជាកូនបងបង្អស់ ចឹងមីងរាប់មិញនឹងជាប្អូនៗទេហោសមីង?

ខៈ នឹងហើយជាប្អូនៗទាំងអស់នឹង នឹងកូនរបស់ខ្ញុំនឹងហាស

កៈ ចឹងមាន4នាក់ ប៉ុន្តែស្រីប៉ុន្មាន ហើយប្រុសប៉ុន្មានដែរអ៊ុំ?

ខៈ ប្អូនមាន4នាក់មានស្រី4នាក់ នឹងប្រុសតែម្នាក់ទេនឹង ហើយប្រុសនឹងឆ្កួតទៀតនឹង

កៈ ម៉េចចឹងមីង?

ខៈ វាឡប់ៗទេ បានប្រុសមួយនឹងឆ្កួតតែម្តងនឹង

កៈ ចឹងាមានបងប្អូនចំនួន5នាក់ណាមីង?

ខៈ ចា៎!នឹងហើយ

កៈ ចុះមីងកាលពីនៅក្មេងៗនឹងមីងធ្លាប់បានធ្វើអីគេខ្លះជាមួយពួកគាត់ដែរទេមីង?

ខៈ ធ្លាប់តែស្ទូងស្រូវ ធ្លប់មូលជើងខោ ស្ទូងស្រែទៅនាំគ្នានាំគោទៅជាន់ប្រដាប់ស្រូវទៅ រោយស្រូវកើប ស្រូវមកច្រកចូលថង់ចឹងទៅនៅក្នុងផ្ទះហើយដាំចេក ដាំអំពៅអីចឹងទៅ

កៈ អ្ហូ!មានច្រើនដែរ?

ខ៖ ហើយនឹងរកទំពាំងយកទៅលក់អីចឹងទៅ បេះស្លឹកស្ពៃ ចេះស្តៅអីចឹងទៅ ចេះចេកទៅ ស្វាយទុំអីនឹង នាំគ្នាយកទៅលក់ទៅបានលុយទៅគ្រាន់ផ្សំធ្វើផ្ទះធ្វើអីនៅនឹងណាស់

ក៖ អូ!ចឹងហោសមីង?

ខ៖ វាចឹងណាស់

ក៖ ចុះកាលពីក្មេងនឹងមីងមានធ្លាប់លេងល្បែងប្រជាប្រិយ៍អី រឺចូលចិត្តលេងអីជាមួយបងប្អូនដែរទេមីង?

ខ៖ អត់ទេអត់ដែរលេងអីទេ គ្រាន់តែថាទៅផ្លាស់គោអីចឹងទៅ ដល់ពេលចឹងនាំគ្នាទៅកាប់ស្លឹកត្នោតទៅ នាំគ្នាដេរប្រេកធ្វើរោងចឹងទៅ

ក៖ ចុះលក្ខណះថាលេងលឹកបាយឡជាមួយបងប្អូនក៏មីងមិនដែរធ្លាប់ដែរហោសមីង?

ខ៖ បាយឡឹកបាយឡនឹងធ្លាប់លេងម្តងនឹង លេងអាគេហៅថាលេងបាយខំអីគេនោះនឹង

ក៖ អូ!លេងបាយខំហោសមីង?

ខ៖ ចា៎!អាគេជីករណ្តៅចេះនឹង

ក៖ អាមានខ្ទៅនឹងហោសមីង?

ខ៖ ហើយគេដាក់ខ្ទៅនឹងគេធ្វើចេះនឹង

ក៖ លក្ខណះគេដាក់មាន6រុនៗនឹងមែនទេមីង?

ខ៖ នឹងហើយគេដាក់6រុននឹង គេថាស៊ីឃ្លាំងមឿងអីចឹងទៅកាលពីជំនាន់ណុងនៅតូចៗនឹង

ក៖ ចុះមានលក្ខណះថាមានលេងអីទៀតទេ លក្ខណះថាលេងចុយលេងអីចឹង?

ខ៖ មានតែលេងចឹងបើចូលឆ្នាំលេងលាក់កន្សែងនឹង ហើយនឹងលេងដណ្តើមស្លឹកឈើនឹង

ក៖ អូ!ចឹងលេងដណ្តើមស្លឹកឈើណាមីង?

ខ៖ នឹងហើយមានតែប៉ុណ្ណឹង

ក៖ ចុះមានលេងបោះអង្គុញ ទាញព្រាតនឹងវិញមីង?

ខ៖ នឹងហើយបោះអង្គុញ ទាញព្រាតនឹង លេងគួកខ្មងអីនឹងណាស់

កៈ  ចុះប្អូនរបស់មីងនឹងសព្វថ្ងៃគាត់នៅណាដែរមីង?

ខៈ  នៅទាំងអស់នឹង

កៈ  នៅស្រុកនឹងទាំងអស់នឹងហោសមីង?

ខៈ  ប៉ុន្តែបាត់ម្នាក់ហើយនឹងប្អូនរបស់ខ្ញុំនឹង

កៈ  ម៉េចចឹងមីង?

ខៈ  វាចេញទៅនឹងអស់20ឆ្នាំហើយនឹង

កៈ  ប៉ុន្តែឥឡូវនឹងនៅតែមិនដឹងដំណឹង?

ខៈ  អត់ដឹងដំណឹងទេ

កៈ  អត់ដឹងថាគាត់ទៅណាទេហោសមីង?

ខៈ  អត់ដឹងថាទៅណាដែរទេនឹង

កៈ  ប៉ុន្តែបងប្អូនដែរនៅនឹងគឺគាត់នៅនឹងទាំងអស់នឹងហោសមីង?

ខៈ ចាំ!នៅនឹងឯងនឹង

កៈ  ចុះពួកគាត់រកស៊ីធ្វើការងារអីគេដែរទៅមីង?

ខៈ  ពេលដែរវាការនឹងវាទើបតែមានប្ដីហើយនឹង ប្អូនរបស់ខ្ញុំនឹងឈ្មោះម៉េង
នឹងប្ដីរបស់វានឹងឈ្មោះឈាន ទៅណាស់
ដល់ពេលអាប្ដីនឹងមកនិយាយជាមួយម៉ែរបស់ខ្ញុំនឹងថា មីងម៉េងនឹងរត់តាមប្រុសផ្សេងទៅ

កៈ  អូ្ន!ម៉េចចឹងមីង?

ខៈ  រួចបានបាត់ដំណឹងសូន្យតែម្ដងនឹង
ហើយបើសិនជានិយាយរបៀបនឹងបើម៉ែរបស់ខ្ញុំជាង្នកគោជំហរឹង
មាំវិញហាសត្រូវប្ដឹងប៉ូលីសប៉ុស្ដិ៍អោយវៃខ្ទោះហើយនឹង
ពីព្រោះបើមានទៅតាមប្រុសផ្សេងនឹងត្រូវទៅ យកកូននឹងអោយអញ់សិនហើយនឹង

កៈ  បាទមីងត្រូវមីង?

ខ៖ ហេងស៊ុយវាយកអ្នកផ្សេងទៅវាចោទកូនយើងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ ហើយយកមីចុងទៅហើយអាកូនរបស់យើងចេះតែបាត់ពីយើងទៀតនឹង

ក៖ ចឹងយើងមិនដឹងទេណាមីង?

ខ៖ យើងមិនដឹងថាគំនិតវារបៀបណាៗយើងមិនដឹងទេ

ក៖ អូ!បាទមីង?

ខ៖ ហើយតាំងពីណុងមកកូនណុង ប្អូនរបស់ខ្ញុំនឹងមិនដែរមកស្រុកភូមិវិញទេនេះ មិនដែរមកផ្ទះទេនឹង

ក៖ ចឹងបាត់រហូតតែម្តងនឹង?

ខ៖ រហូតតែម្តងនឹងអស់20ឆ្នាំហើយនឹង

ក៖ ឥឡូវនឹងនៅតែមិនដឹងដំណឹងទេ?

ខ៖ អត់ដឹងសោះមួយអឺកក៏មិនដឹងដែរនឹង

ក៖ អត់ដឹងថាគាត់ទៅណាអីទេ?

ខ៖ អត់ដឹងថាស្លាប់រឺមួយក៏រស់ រឺក៏ត្រូវគេប្លន់អី រឺត្រូវគេកាត់ក ដាច់ក្បាលអីកផមិនបានដឹងដែរនឹង

ក៖ ចុះគាត់នឹងជាប្អូនរបស់អ៊ុំទីប៉ុន្មានដែរមីង?

ខ៖ វាជាប្អូនរបស់ខ្ញុំទី2នឹងហោសបន្ទាប់ពីខ្ញុំនឹងទៅនឹង

ក៖ អូ!ចឹងទេហោសមីង?

ខ៖ នឹងហើយបាត់បន្ទាប់ពីខ្ញុំទៅនឹងណាស់

ក៖ ចុះបើប្អូនបន្ទាប់ទៀតនឹងតើពួកគាត់នឹងនៅណាដែរមីង ហើយពួកគាត់ធ្វើអីគេដែរមីង?

ខ៖ គេមានគ្រួសារនឹងមានប្តីប្រពន្ធអស់ហើយនឹងគេនៅជិតៗនឹងទេ មីមួយនឹងត្រឹមល្វល មីមួយទៀត នឹងត្រឹមនឹងទេនេះ

កៈ ប៉ុន្តែគាត់រកស៊ីអីគេវិញមីង?

ខៈ វារកស៊ីដឹកមេគោនឹងលក់បន្លែនឹង ស៊ីឈ្នួលជីករណ្តៅចេក នឹងជីកអីអោយគេចឹងទៅ

កៈ បាទគាត់ធ្វើការចឹងហោសមីង?

ខៈ នឹងហើយនឹងស៊ីឈ្នួលច្រូតស្រូវអីអោយគេចឹងទៅណាស់ ចុះយើងខ្មែរធ្វើចឹងហាស

កៈ បាទមីងចុះឪពុករបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខៈ គាត់មានឈ្មោះតា ដុល

កៈ ចុះឥឡូវនឹងគាត់អាយុប៉ុន្មានមីងមានចងចាំទេ?

ខៈ បើនៅនឹងអាយុ76ឆ្នាំហើយនឹង

កៈ អូ៎!អាយុ76ឆ្នាំហោសមីង?

ខៈ ចុះបើម៉ែនឹងគាត់អាយុ66ឆ្នាំពីព្រោះគាត់បងម៉ែនឹងមួយខ្ទង់នឹង

កៈ អូ៎!ចឹងគាត់បងគ្នា10ឆ្នាំ?

ខៈ គាត់ឆ្នាំរោងដូចគ្នាមែនប៉ុន្តែគាត់បងគ្នាមួយខ្ទង់នឹង
ហើយគេថារោងនឹងរោងនឹងកុំអោយយកគ្នា បើយកទៅមើលគ្នាមិនយល់ទេ
ដល់ពេលដែរយកទៅឪពុករបស់ខ្ញុំនឹងស្លាប់រទេះសេះបុកបាក់កនឹងណាស់

កៈ ចឹងឪពុករបស់មីងនឹងម្តាយរបស់មីងនឹងឆ្នាំរោងដូចគ្នានឹង?

ខៈ ឆ្នាំរោងដូចគ្នាប៉ុន្តែបងគ្នាមួយខ្ទង់នឹង

កៈ ចឹងគាត់បងគ្នាមួយខ្ទង់នឹងហោសមីង
ចុះម្តាយរបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ គាត់មានឈ្មោះយាយអ៊ឹម

កៈ ចុះឪពុករបស់មីងនឹងគាត់កើតនៅណាដែរមីងមានដឹងទេ?

ខៈ ឪពុករបស់ខ្ញុំកើតនៅស្រុកទ្រាននេះនឹង

កៈ គាត់កើតនៅស្រុកទ្រាន ចុះម្តាយរបស់មីងវិញ?

ខៈ ម៉ែរបស់ខ្ញុំនឹងគាត់កើតនៅវាលខ្សាច់នេះនឹង

កៈ ចុះឪពុករបស់មីងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ គាត់ធ្វើការអាតែឈើទេ

កៈ អូ្ន!គាត់ជាអ្នកអាឈើណាមីង?

ខៈ គាត់អានឹងដៃនឹង គាត់ដើរអាអោយគេក្រប់កន្លែងនឹង

កៈ នឹងសំរាប់គាត់នឹងគេជួលគាត់ទៅ?

ខៈ នឹងហើយគេជួលគាត់ទៅនឹង
គាស់យកលុយអោយម៉ែទិញអង្ករស៊ីហើយគាត់ទៅរកត្រីដែរគាត់ ដាក់ឡបនឹង

កៈ ចឹងគាត់បង់ត្រីទៀត?

ខៈ នឹងហើយគាត់ដាក់ចឹងបានអណ្តើក បានត្រី បានបង្កងបានអីចឹងណាស់
មិនមែនអាតែឈើនឹងទេ គាត់អាឈើផង គាត់ដាក់ឡបផងនឹង

កៈ ចុះគាត់ជាមនុស្សបែបណាដែរមីងគាត់ស្លូត រឺមួយក៏កាចដែរមីង?

ខៈ គាត់ស្លូតទេ មិនចេះមាត់ទេនឹង

កៈ ចុះម្តាយរបស់មីងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ
ម្តាយរបស់ខ្ញុំនឹងគាត់រកបន្លែបន្តិចបន្តួចនឹងប៉ុន្តែឥឡូវនឹងគាត់យកប្តីចុងនឹងទៀតហើយនឹង

កៈ អូ្ន!ចឹងហោស ចុះម្តាយរបស់មីងនឹងគាត់ស្លូត រឺមួយក៏កាចដែរមីង?

ខៈ ម្តាយរបស់ខ្ញុំនឹងគាត់ស្លូតទេនឹង មិនដែរស្តីអោយកូនមួយម៉ាត់ទេ

កៈ ចុះមីងមានចងចាំអីកាលពិមីងនៅជាមួយម្តាយឪពុករបស់មីងដែរទេ
ដូចជាធ្លប់មានអនុស្សាវរីយ៍អី ជាមួយគ្នាដែរទេ?

ខ៖  ខ្ញុំចងចាំតើ ខ្ញុំមកពីលេងវត្តពេលដើរមកពីចូលឆ្នាំអីចឹងទៅ ហើយគាត់ដាំបាយអីអោយស៊ីចឹងទៅ ណាស់គាត់មកពីរកត្រីទៅ គាត់មកពីអាឈើទៅ នឹងនាំកូនដេកទៅ

ក៖  អូ!ចឹងហោសមីង?

ខ៖  ឪពុករបស់ខ្ញុំនឹងស្លូតណាស់គាត់មិនដែរមាត់អោយកូនមួយម៉ាត់ទេនេះ

ក៖ ចុះឪពុករបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅមីងដែរទេមីង?

ខ៖  គាត់ប្រាប់ដែរតើ!គាត់អាតែឈើនឹង គាត់រកតែត្រីនឹង

ក៖  ចឹងហោសមីងគាត់ធ្វើតែចឹងទេ?

ខ៖  នឹងហើយគាត់មានមុខរបរតែ2មុខទេនឹង

ក៖ ចុះម្ដាយរបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅមីងដែរទេនឹង?

ខ៖  នៅក្មេងនឹងយាយនឹងគាត់យកប្ដីច្រើននាក់ណាស់

ក៖  អូ!ចឹងគាត់មានប្ដីច្រើនហោសមីង?

ខ៖  ប្ដីទី1របស់គាត់នឹងមានឈ្មោះអីណាផ្សេងទៅឈ្មោះតារុណាណាណោះ ហើយដល់ពេលដែរមកយក ឪពុករបស់ខ្ញុំនឹងឈ្មោះតាដុល

ក៖  ចុះយាយតាខាងម្ដាយរបស់មីងនឹងមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖  ខ្ញុំស្គាលតើ!

ក៖  គាត់មានឈ្មោះអីគេដែរមីង?

ខ៖  យាយម្ដាយរបស់ខ្ញុំនឹងឈ្មោះយាយ ប៊ូ ម្ដាយរបស់តាដុលខ្ញុំ ខ្ញុំស្គាល់ទាំងអស់នឹងខ្ញុំកើតនឹងហាស ខ្ញុំឃើញគាត់

កៈ អូ៎!ចឹងហោសមីងស្គាល់ទាំងអស់?

ខៈ
កាលពីខ្ញុំនៅតូចអីនឹងយាយរបស់ខ្ញុំនឹងនៅបុកត្រកៀតដាក់អោយជ្រូកនឹងហោសពេលដែរ គាត់ ស្លៀកសំពត់ទៅចង្កេះគាត់រាងកោងៗហាសណាស់ ប៉ុន្តែគាត់ខ្ពស់គាត់មិនមែនកោងទេ ប៉ុន្តែគាត់ខ្ពស់នឹង

កៈ អូ៎!បាទមីងបាទ?

ខៈ គាត់ខ្ពស់ជាងខ្ញុំគាត់ប្រហែលជាមួយម៉ែត្រចិតអីនឹង យាយរបស់ខ្ញុំនឹងខ្មៅស្រអែម ហើយយាយរបស់ ខ្ញុំនឹងស្អាតណាស់គាត់មិនដូចខ្ញុំទេនឹងអត់ដូចថៅៗទេនឹង

កៈ ចុះយាយតាខាងម្ដាយមីងមានដឹងថាគាត់អាយុប៉ុន្មានដែរទេមីង?

ខៈ យាយតាម៉ែរបស់ខ្ញុំនឹងទើបតែស្លាប់ទេនឹង

កៈ ប៉ុន្តែគាត់ប្រហែលជាអាយុខ្ទង់ប៉ុន្មានដែរទៅមីង?

ខៈ ម្ដាយម៉ែរបស់ខ្ញុំយាយគីមនឹងអាយុ83ឆ្នាំ

កៈ ចុះតាវិញមីង?

ខៈ
តារបស់ខ្ញុំនឹងគាត់ស្លាប់នៅជំនាន់ពលពតនឹងតាស្រេងនឹងមិនដឹងថាគាត់ទៅខាងណាទេ ខ្ញុំកើតមកនឹងមិនឃើញទេនឹង

កៈ ប៉ុន្តែយាយតាខាងម្ដាយនឹងគាត់កើតនៅណាមីងមានដឹងទេ?

ខៈ គាត់កើតនៅល្អាងនឹង

កៈ ចឹងគាត់កើតនៅល្អាងណាមីង?

ខៈ តាស្រេងនឹងគាត់កើតនៅល្អាងនឹង

កៈ ប៉ុន្តែយាយវិញមីង?

ខៈ យាយនឹងនៅវាលខ្សាច់នឹង យាយគីមនឹងកើតនៅវាលខ្សាច់

កៈ ចុះយាយតាខាងឪពុកវិញមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ឪពុករបស់ខ្ញុំហោស?

កៈ អត់ទេយាយតាខាងឪពុកហាស?

ខៈ ខាងឪពុកនឹងមិនដឹងទេ ខ្ញុំដឹងតែទូតតែម្ដងនឹង ដឹងតែតាស៊ីន នឹងយាយប៊ូនឹងប្ដីប្រពន្ធរបស់គាត់

កៈ អូ៎!ចឹងហោសមីង?

ខៈ ប្ដីប្រពន្ធរបស់គាត់នឹងគាត់កើតឪពុករបស់ខ្ញុំនឹង

កៈ ចុះមីងមានដឹងថាគាត់កើតនៅណាមីងមានដឹងទេ?

ខៈ គាត់នៅទ្រាននឹងគាត់នៅផ្ទះសព្វថ្ងៃនៅផ្ទះ3-4ខ្នងនៅសព្វថ្ងៃនឹង

កៈ គាត់នៅរស់សព្វថ្ងៃហោសមីង?

ខៈ អត់ទេគាត់ស្លាប់បាត់ហើយប៉ុន្តែនៅថៅៗ

កៈ អូ៎!ចឹងនៅតែថៅៗទេ?

ខៈ នៅថៅទូតនឹង

កៈ ចុះគាត់អាយុប៉ុន្មានដែរមីងមានដឹងទេតាយាយហាស?

ខៈ យាយប៊ូរបស់ខ្ញុំនឹងគាត់ស្លាប់អាយុ76ឆ្នាំ

កៈ ចុះគ្រួសាររបស់មីងនឹងមកនៅនឹងយូរនៅមីង?

ខៈ នៅតាំងពីតូចៗមកម៉េសនឹង

កៈ នៅតាំងពីតូចៗចឹងមានន័យថាជាង40ឆ្នាំហើយណាមីង?

ខៈ ចា៎!នឹងហើយតាំងពីខ្ញុំនៅស្លៀកសំពត់ត្រឹមជង្គង់មកម្ល៉េស

កៈ ចុះមីងមានបងប្អូនរឺមួយក៏សាច់ញ្ញាតិណា ដែររស់នៅក្រៅប្រទេសទេមីង?

ខៈ អត់ទេ

កៈ នៅថៃ វៀតណាមអីក៏អត់មានដែរ?

ខៈ ថាវាបាត់ប្អូនមួយនឹងណាស់ វាមិនដឹងថាទៅខាងណានឹងណាស់

កៈ ប៉ុន្តែចង់និយាយថាបងប្អូនជីដូនមួយអីក៏អត់មានដែរ?

ខៈ អត់មានទៅណាទេ រាល់ថ្ងៃនឹងបាត់ប្អូនបង្កើតមួយ នឹងបាត់កូនអាយុ2ឆ្នាំមួយដែរនឹង

កៈ អើរម៉េចចឹងមីង?

ខៈ វាទៅធ្វើការងារថាទៅធ្វើខាងសំអាងនៅភ្នំពេញនឹង
ហើយវាបាត់ដំណឹងមិនឃើញតេមកផ្ទះវាបាត់ ទូរស័ព្ទ

កៈ អ៎ូ!ចឹងហោសមីង?

ខៈ ហើយខ្ញុំរកគ្រូទាយទៅគេថានាំវាទៅថៃ ប៉ុន្តែបន្តិចទៀតនឹងនាំគ្នាបងផ្ទះវិញហើយនឹង

កៈ ប៉ុន្តែយើងមិនទាន់ដឹងដំណឹងទេឥឡូវនឹង?

ខៈ អត់ទាន់ដឹងដំណឹងទេពីព្រោះវាបាត់លេខ
បើមានលេខទូរស័ព្ទគ្រាន់បានតេទៅឆ្លើយឆ្លងហើយនឹង

កៈ ប៉ុន្តែគ្រាន់ថាគាត់វិញគាត់ដឹងថាគ្រួសាររបស់គាត់នៅនឹង ប៉ុន្តែគ្រាន់ថាម៉េចទៅ?

ខៈ ដឹងតើ!

កៈ ចុះស្វាមីរបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ គាត់មានឈ្មោះថា

កៈ ចុះមីងមានដឹងថាមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេមីង?

ខៈ ខ្ញុំនៅចងចាំតើ!

កៈ នៅថ្ងៃខែឆ្នាំណាដែរមីង?

ខៈ នៅក្នុងសៀវភៅគ្រួសារហោស

កៈ ប៉ុន្តែឥឡូវនឹងមីងមិនដឹងទេ មីងអត់ដឹងថាមីងការនៅថ្ងៃខែឆ្នាំណាទេមីង?

ខ៖ ខ្ញុំការតាំងពីអាយុ18ឆ្នាំមកហើយនឹង

ក៖ ប៉ុន្តែមីងការភ្លាមមីងមានកូនភ្លាមរឺមួយក៏យ៉ាងម៉េចដែរមីង?

ខ៖ មាននឹងហើយ

ក៖ ប៉ុន្តែកូនមីងនឹងកូនបងគេអាយុប៉ុន្មានឆ្នាំដែរមីង?

ខ៖ វាអាយុ24ឆ្នាំហើយនឹងវាឆ្នាំច នេះកូនរបស់នឹងវាប៉ុនៗនេះនឹង

ក៖ គាត់កូនបងរបស់មីងហោស?

ខ៖ អានឹងកូនប្រសារទេ ប៉ុន្តែអាកូនបង្កើតនឹងវាអាយុស្គរអានឹង

ក៖ អ៉ូ!គាត់អាយុ24ឆ្នាំហោសមីង?

ខ៖ វាឆ្នាំច

ក៖ ចឹងមីងការអស់ប្រហែលជា25ឆ្នាំហើយណាមីង?

ខ៖ ចាំ!ប៉ុណ្ណឹងឯង

ក៖ ចុះនៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍នឹងគិតថាមីងជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ម្តាយឪពុក មីងជាអ្នករៀបចំអោយដែរមីង?

ខ៖ ម៉ែឪជាអ្នករៀបចំអោយតើនឹង

ក៖ ចុះពេលដែរប្តីរបស់មីងចូលស្តីដណ្តឹងមីងនឹងមានជាជំនូនអត់ទេមីង?

ខ៖ មានដែរតើ!នឹង

ក៖ មានជាប៉ុន្មានដែរមីងអាចប្រាប់បានទេ?

ខ៖ មានតែ4-10តុទេការតូចដែរនឹង

ក៖ អ៉ូ!ចឹងការនឹងតូចដែរទេហោសមីង?

ខ៖ នឹងហើយមិនការធំដូចគេទេនឹង ពីព្រោះតែខ្ញុំក្រ

កៈ ចុះមីងអាចប្រាប់ខ្ញុំបានទេថាប្តីរបស់មីងបានជួបមីងនៅពេលណា ហើយបានស្រលាញ់គ្នាប៉ុន្មានឆ្នាំ បាកការជាមួយគ្នាអីចឹងហាសមីង?

ខៈ
ខ្ញុំនឹងមិនដឹងទាំងស្គាល់គេផងនឹងនេះស្រាប់តែគេមកតែម្តងនឹងប៉ុន្តែបងប្អូនខាងឪពុករបស់ខ្ញុំនឹង

កៈ ប៉ុន្តែខាងគេនឹងចាប់អារម្មណ៍យូរហើយមែនទេ?

ខៈ ខ្ញុំមិនដឹងខ្លួនទេគេមកតែម្តងនឹង

កៈ ចុះមីងមានចេះអានរឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរមីង?

ខៈ អក្សរខ្មែរនឹងខ្ញុំមិនសូវចេះទេ ប៉ុន្តែបើគ្រូសរសេរអោយខ្ញុំអានទៅ

កៈ ប៉ុន្តែមីងរៀនបានថ្នាក់ទីប៉ុន្មានដែរមីង?

ខៈ ខ្ញុំរៀនបានថ្នាក់ទី2-3ទេនឹង

កៈ ចឹងមីងរៀនបានតិចដែរហោសមីង?

ខៈ ចា៎!ប៉ុន្តែបើគ្រូធ្វើអីៗអោយចឹងដូចជាសំបុត្រកំណើត រឺសៀវភៅគ្រូសារចឹងទៅខ្ញុំអានអោតទៅវិញនឹង សុទ្ធតែអក្សរគ្រូទេនឹង

កៈ ប៉ុន្តែមីងរៀននឹងនៅណាដែរ?

ខៈ បើខ្ញុំសរសេរនឹងអត់កើតទេកខ្វក់ទេនឹង

កៈ ប៉ុន្តែមីងបានរៀននៅណាដែរមីង?

ខៈ ខ្ញុំរៀននៅសាលាថ្មគោលពីតូចនឹង

កៈ ចឹងមីងធ្លាប់មានមិត្តភក្តិជិតស្និទ្ធិដែរធំធាត់មកជាមួយគ្នាដែរទេមីង?

ខៈ មិនសូវជាមានទេ

កៈ ប៉ុន្តែមិត្តភក្តិរបស់មីងនឹងមានឈ្មោះអីគេដែរមីង ចង់និយាយថាអ្នករៀនជាមួយគ្នាអីដែរចឹងណាស់?

ខ៖ គេនៅខាងថ្មគោលនឹងដែរ

ក៖ ប៉ុន្តែគេមានឈ្មោះអីគេដែរមីង
មីងអាចប្រាប់ឈ្មោះប៉ុន្មាននាក់ដែរមីងគិតថាមីងចងចាំទេ?

ខ៖ នឹងយើងធ្លាប់រៀនជាមួយគ្នាឈ្មោះតាច្រឹកធំហាសណាស់
នឹងកាលពីតូចៗរៀនជាមួយគ្នា នឹងចែម៉ាចអីដែរនឹង

ក៖ ប៉ុន្តែមីងធ្លាប់មានអនុស្សាវរីយ៍អីគេជាមួយពួកគាត់ខ្លះដែរមីង?

ខ៖ ដូចជាគ្មានអនុស្សាវរីយ៍អីគេទេនឹង

ក៖ លក្ខណៈដើរលេងអីចឹង?

ខ៖ ដល់ម៉ោងចូលរៀនចឹងចូលរៀនទៅនឹងណាស់
ដល់ពេលដែរដល់ម៉ោងមកផ្ទះចឹងមកផ្ទះរៀងខ្លួនចឹង
មកណាស់ម៉ែឪគេនៅខាងថ្មគោលគេទៅថ្មគោលចឹងទៅ
ហើយម៉ែឪយើងខាងនឹងក៏មកខាងនឹងមក

ក៖ អូ៎!ចឹងទេហោសមីង?

ខ៖ ប៉ុន្តែណាប្រកែកគ្នាឈ្លោះគ្នាចឹងទៅ វៃគ្នារឿងសៀវភៅគ្នាបន្តិចបន្តួចអីចឹងទៅប៉ុន្តែដឹង
កាលនៅពីតូចនឹងមិនដឹងអីទេ វៃគ្នាទាញសក់គ្នាអីចឹងទៅណាស់

ក៖ អូ៎!វៃតែគ្នាទៅ?

ខ៖ នឹងហើយប៉ុន្តែដល់ពេលដែរធំឡើងនឹងដឹងខុស ដឹងត្រូវចឹងទៅមិនដែរមានអីទេ

ក៖ បាទចឹងមីង?

ខ៖ កាលនៅពីតូចនឹងច្របាប់គ្នារឿងសៀវភៅតើ
ដល់ពេលដែរធំឡើងយើងនិយាយគ្នានឹង

ក៖ ចង់និយាយថាយើងឈ្លោះគ្នាហោសមីង?

ខ៖ ចា៎!នឹងហើយ

ក៖ ប៉ុន្តែឈ្លោះគ្នាហើយត្រូវគ្នាវិញតើហីមីង?

ខ៖  នឹងហើយត្រូវគ្នាវិញនឹង ឥឡូវនឹងត្រូវគ្នាវិញហើយនឹង ពេលណុងគ្រូស្តីអោយថាមករៀនកុំឈ្លោះគ្នា ចឹងអីគ្រូវៃតុវៃអីចឹងទៅណាស់

ក៖  លក្ខណះឈ្លោះគ្នាយូរហោសមីង?

ខ៖  ឈ្លោះគ្នាយើងអង្គុញជិតគ្នាអីចឹងទៅណាស់

ក៖  ដល់ពេលហើយយើងលក្ខណះថាអត់និយាយរកគ្នាអីចឹងហោសមីង?

ខ៖  នឹងហើយចឹងប៉ុន្តែឥឡូវនឹងធំអស់ហើយ ហ៎យមានប្តីប្រពន្ធរៀងខ្លួនទៅដឹងហើយនឹង លែងភ្លើដូចពីកាលនៅតូចៗទៀតហើយនឹង

ក៖  ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរទេមីង?

ខ៖  ភាសាគេខ្ញុំមិនចេះទេខ្ញុំចេះតែភាសាឯងនឹង បើខ្ញុំចេះភាសាគេនិងខ្ញុំនឹងទៅបកប្រែភាសាគេបាន លុយចាយហើយខ្ញុំចេះតែខ្មែរទេនឹង

ក៖  ចុះវៀតណាម ថៃអីក៏មីងមិនចេះដែរ?

ខ៖  ភាសាវៀតណាម ថៃអីក៏អត់ចេះទៀតនឹង

ក៖  អូ៎!ចឹងមីង?

ខ៖  ពីព្រោះខ្ញុំមិនបានរៀនច្រើនទេ បើខ្ញុំបានរៀនច្រើននឹងខ្ញុំចេះហើយនឹង

ក៖  ចុះមីងមានធ្វើស្រែចំការទេមីង?

ខ៖  ធ្វើតើ រាល់ថ្ងៃនឹងធ្វើ

ក៖  ចុះមីងធ្វើអីគេខ្លះដែរស្រែចំការនឹងមីង?

ខ៖  នឹងដូចជាដាំចេក ដាំអំពៅ ដាំជំឡូងអីចឹងណាស់

ក៖  ចឹងដាំច្រើនមីង?

ខ៖  នឹងហើយជួលប្អូនដាំសណ្តែកនៅផ្ទះអីចឹងណាស់ ខ្ញុំធ្វើចំការចឹងៗទេនឹង

ក៖  ចុះមីងមានធ្លាប់បើកអាជីវកម្មលក់ដូរអីទេមីង?

ខ៖  បើកបានម្តងខាងដើមខាងចុងនឹង កូនវាចេះតែមិនប្រឹងធ្វើ លក់ដែរតើ មាននុំនែកចំណីអី ស្រាអីនឹង ដែរនឹងតើ មានបីចេង សំរាប់ធ្វើម្ហូបអីចឹងណាស់

ក៖  ចុះមីងមានធ្លាប់ចិញ្ចឹមសត្វទេមីង ដូចជាចិញ្ចឹមមាន់ គោ ក្របីអីចឹងណាស់?

ខ៖  កាលពីដើមនឹងចិញ្ចឹមកាលពីនៅក្មេងមានចិញ្ចឹមជ្រូក ចិញ្ចឹមគោនឹងដែរ ប៉ុន្តែឥឡូវនឹងលក់អស់ហើយនឹង

ក៖  ប៉ុន្តែចិញ្ចឹមលក្ខណះជាកសិដ្ឋាន រឺមួយចិញ្ចឹមជាលក្ខណះគ្រួសារដែរមីង?

ខ៖  ចិញ្ចឹមជាមួយប្តីប្រពន្ធ ចិញ្ចឹមលក្ខណះគ្រួសារជាមួយគ្នានឹងណាស់

ក៖  អូ៎!ចិញ្ចឹមលក្ខណះគ្រួសារហោសមីង?

ខ៖  នឹងហើយមានទិញកន្ទួកដាក់អោយស៊ីទៅណាស់កាលកូនវានៅតូចៗនឹងណាស់

ក៖  ចុះមីងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតើមីងមានធ្លាប់ធ្វើការងារអីគេខ្លះដែរមីង?

ខ៖  ធ្វើតែស្រែចំការរហូតនឹង

ក៖  ចឹងធ្វើតែចឹងតរហូតតែម្តងនឹងមីង?

ខ៖  ចា៎!គ្មានដែរដើរទៅណាទេនឹង

ក៖  ចុះមីងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតើជីវិតរបស់មីងនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរ មីង?

ខ៖  នៅតែចឹងនៅតែទៅធ្វើស្រែចំការគេដដែលនឹង នៅតែធ្វើខ្ញុំគេដដែលនឹងទៅរើសចន្ទីអីចឹងទៅ ទៅដកដំឡូងអោយគេចឹងទៅ

ក៖  បាទមីងចឹង?

ខ៖  ដូចថាយើងវាមិនទាន់មានដូចថាសំរាកមិនទាន់កើតទៅណាស់ ត្រូវគេជួលចឹងទៅទៅនឹង

ក៖ ចុះជីវភាពនឹងសុខភាពយ៉ាងម៉េចដែរមីង?

ខ៖ អត់អីទេមិនដែរឈឺទេនឹង

ក៖ អ៊ូ!ល្អហើយចឹងហោសមីង?

ខ៖
ចាំ!ចេះតែទៅរួចហើយនឹងសំរួលតាមគេចឹងទៅដាក់តាមគេថ្លឹងគីឡូតាមគេចឹងទៅណាស់ហើយដកដំឡូងក៏ចឹងដែរគេកាប់
ដាក់ចូលក្នុងធុងចឹងទៅហើយគេវាស់ប៉ោតចឹងទៅយកមកបកសំបក់ ចឹងទៅណាស់
ស៊ីឈ្នួលចឹងមកចេះតែធ្វើតាមគេចឹងហើយនឹង

ក៖ បាទចឹងណាមីង?

ខ៖ ប៉ុន្តែមិនដែរឈឺអីទេប៉ុន្តែមាឧវាតូចនឹង

ក៖ ចុះមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខ៖ នឹងហើយមានសម្លម្ជូរ សម្លប្រហើរអីធម្មតានឹង នឹងស្ងោរប្រហុកស្អុយអីនឹងណាស់ហើយនឹងត្រីអាំង ចៀនស្លចឹងទៅ សំលខ្មែរយើងនឹង

ក៖ ចុះមីងមានចេះច្រៀងដែរទេមីង?

ខ ខ្ញុំច្រៀងចេះតើនឹង ប៉ុន្តែខ្ញុំមិនសូវច្រៀងទេនឹង

ក៖ ចុះមីងចេះច្រៀងបទអីគេដែរមីង?

ខ៖ ចេះតែច្រៀងហើយបទអីក៏ចេះតែច្រៀងហើយនឹង

ក៖ ប៉ុន្តែមីងចូលចិត្តបទចំរៀងដែរ?

ខ៖ ពចាំ!ចំរៀងនឹងខ្ញុំចេះច្រើនណាស់ប៉ុន្តែខ្ញុំមិនច្រៀងទៅ

ក៖ ចុះមីងចូលចិត្តស្តាប់បទសម័យ រឺបទបុរាណដែរមីង?

ខ៖ ខ្ញុំចូលចិត្តស្តាប់បទបុរាណនឹង

ក៖ អូ!ចឹងបទបុរានណាមីង
ចុះមីងគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសារមីងចេះលេងឧបករណ៍ភ្លេងទេមីង?

ខ៖ ភ្លេងនឹងគេអ្នកភ្លេងការផ្សេងនឹង

ក៖ ប៉ុន្តែចង់និយាយមានបងប្អូនរបស់មីងនឹងមាននរណាគេចេះលេងទេ
លក្ខណៈភ្លេងពិនពាត ភ្លេងការ នឹងអកកណ្តុងអីចឹង?

ខ៖ អត់ទេមានគេខ្លះចេះ

ក៖ ចុះផ្ទះរបស់មីងនឹងមានលក្ខណៈបែបណាដែរតាំងពីក្មេង
រហូតមកដល់ពេលនេះហាស?

ខ៖ កាលពីដើមនឹងខ្ញុំក្រទេនឹង មានផ្ទះខ្ទមតូចនឹង

ក៖ ប៉ុន្តែដល់ពេលឥឡូវនឹង?

ខ៖ ឥឡូវនឹងផ្ទះចេះនឹង

ក៖ ចុះផ្ទះរបស់មីងនឹងដូចជាមីងធ្វើដោយខ្លួនឯងរឺក៏មីងជួលគេធ្វើដែរមីង?

ខ៖ ខ្ញុំជួលគេនឹង

ក៖ ចឹងមីងមានដឹងថាផ្ទះនឹងគេមានឧបករណ៍អីគេដែរសំរាប់សាងសងផ្ទះមួយនឹង?

ខ៖ គេយកសរសៃដែក អីនឹងហើយគេថា
អើយខ្ញុំខំប្រឹងធ្វើខ្ញុំគេចឹងទៅដើម្បីអោយមានសសរមួយគ្រឿង ថែមទៀតនឹង
ហើយសសរ2លានទៀត

ក៖ អូ!បាទមីងបាទ?

ខ៖ ទៅរើសច័ន្ទទីចេះតែរើសផ្សំនឹងអាចដាក់សសរមួយទៀតនឹងវាបាបខ្ពស់ស្អាតនឹង

ក៖ បាទមីងត្រូវហើយនឹង?

ខ៖ ចុះបើយើងមិនធ្វើចឹងយើងអ្នកស្រែនឹង

ក៖ បាទមីងចុះមីងគិតថាជំនាញអីដែរមីងគិតថាមីងចេះស្ទាត់ជំនាញខាងធ្វើដែរមីង?

ខ៖ ខ្ញុំបើស្ទាត់ជំនាញជាងគេនឹងមូលចន្ទីនឹង ពីព្រោះដីគេម្នាក់បាន30-40ហត្ថានឹង យើងទៅដល់ស្រុក គេនឹងគេរកតែកម្មករធ្វើទេនឹង

ក៖ ចឹងហោសមីង?

ខ៖ នឹងហើយខ្លាចតែយើងខ្ជិលទេនឹង

ក៖ អ្ហូ!ចឹងមានន័យថាកន្លែងដែរមីងទៅធ្វើនឹងគេត្រូវការមនុស្សច្រើន?

ខ៖ នឹងហើយខ្លះនឹងគេចាក់ជ័រកៅស៊ូទៀតនឹង

ក៖ ប៉ុន្តែគេអោយប្រាក់ខែគួរសមដែរណាមីង?

ខ៖ ប្រាក់ខែគេអោយតើ!នឹង អង្ករគេធ្វើអោយស៊ីតើ អោយតែយើងធ្វើអោយគេថៅកែគេជួលទេនឹង

ក៖ បាទចឹងមីង?

ខ៖ ប៉ុន្តែខ្លួចតែយើងខ្ជិលមិនទៅចឹងណាស់

ក៖ ចុះមីងគិតថាម្តាយឪពុករបស់មីងគាត់ធ្លាប់បង្រៀនពីជំនាញអីទៅមីងដែរទេ?

ខ៖ អត់ដែរបង្រៀនខ្ញុំទេតែខ្ញុំនឹងទៅសាលាហោស គាត់មិនដែរប្រាប់ខ្ញុំទេតែបើឪពុករបស់ខ្ញុំវិញគាត់តែ ធិមគេទេនឹង

ក៖ ចុះមីងអាចប្រាប់ខ្ញុំពីកាលលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះចឹងទៅណាស់មីងបានទេ?

ខ៖ កាលនៅពីតូចនឹងដូចជាមិនមានការលំបាកអីផងនឹង ពីព្រោះឪពុកគាត់នៅរស់នឹង រួចម្តាយនឹងគាត់ដាំតែបាយអោយស៊ីទៅ យើងទៅតែរៀនតិចតួចចឹងទៅពេលមកវិញអង្គុយលេងខ្លះអីខ្លះ ចឹងទៅណាស់ ប៉ុន្តែគាត់ដើរធ្វើខ្ញុំគេដាំជំឡូរនឹងអោយគេចឹងដែរ

ក៖ បាទចឹងមីង?

ខ៖ មកវិញមើលគោអីចឹងទៅ ដាក់បាយអោយជ្រូក

ក៖  ចុះកាលពីជំនាន់ពលពតនឹងមីងធ្លាប់ជួបការលំបាកអីគេដែរទៅមីង?

ខ៖  ពលពតនឹងខ្ញុំនៅតូចៗទេ ម៉ែរបស់ខ្ញុំនឹងគាត់ថាទើបតែកើតទេនឹង

ក៖  ចឹងមីងនៅតូចទេ?

ខ៖  ខ្ញុំកើតនៅឆ្នាំ1973នឹងចឹងខ្ញុំនៅតូចទេម៉ែនៅបីឆ្លងស្ទឹងនៅឡើយនឹង

ក៖  ចឹងគេមិនអោយមីងទៅធ្វើអីទេណាមីង?

ខ៖  ខ្ញុំធ្វើអីកើតបើឪពុកម្ដាយនៅបំបៅកូននៅតូចនឹង
ប៉ុន្តែគ្រាន់តែថាជំនាន់អាគ្រាប់ផ្លោងនឹងគាត់ច្រើន តែរត់នឹង គាត់ក្រាបនឹង

ក៖  ប៉ុន្តែពេលណុងមីងដឹងដែរហោសមីង?

ខ៖  ចុះម៉ែរបស់ខ្ញុំនឹងគាត់ប្រាប់

ក៖  ប៉ុន្តែគ្រួសាររបស់មីងនឹងនៅណាដែរមីង?

ខ៖  គ្រួសាររបស់ខ្ញុំនឹងនៅស្រុកផ្អៅនេះ

ក៖  ចុះឪពុកម្ដាយរបស់មីងនឹងធ្វើអីគេដែរទៅមីង?

ខ៖  ម៉ែរបស់ខ្ញុំនឹងធ្វើតែបន្លែធ្វើចំការនឹង ស្ទូងស្រូវនឹង

ក៖  អ្ហូ!ជំនាន់ពលពតនឹងគេអោយធ្វើចឹងដែរ?

ខ៖  ចា៎!គេអោយចិញ្ច្រាំកន្ត្រាំងខែតអីដាក់ដី
ហើយគេអោយបបរបាយជ្រូកនឹងម៉ែខ្ញុំថាបបរទៅកូរឆ្នាំង
ហើយគាត់ថាធ្លាប់ចុកថ្នាំនឹងទៅក្នុងបបរនឹង

ក៖  ចុះយ៉ាងម៉េចទៅមីង?

ខ៖  ហើយក្របួចក្ដួចយកមកចុកវិញនឹងគាត់និយាយហា
គាត់ថាកូននៅទាញបៅពីមុខទាញពីក្រោយនឹង
គេដាក់ផែនការណ៍អោយបបរបាយជ្រូកនឹងមួយថ្ងៃ20ខ្ទះនឹង

ក៖  ប៉ុន្តែពេលណុងកើតតែមីងម្នាក់ឯងតើហីមីង?

ខ៖ ចាំ!កើតខ្ញុំមួយមុនគេនឹង

ក៖ ប៉ុន្តែប្អូនៗរបស់មីងនឹងកើតមិនទាន់ទេពេលណុងហោស?

ខ៖ កើតដែរប៉ុន្តែនៅតូច

ក៖ អូ៎!ចុះពេលដែរមីងមានគ្រួសារនឹងមីងគិតថាមានការលំបាកអីគេខ្លះដែរទៅមីង?

ខ៖ អត់មានពិបាកអីទេកើតតែកូននឹងវាទៅរកអោយស៊ី
វាទៅរកចឹងទៅយើងនៅតែដាំបាយចឹងទៅដល់
ពេលចឹងពោះធំកើតចឹងទៅកូនរបស់ខ្ញុំនឹងបាន5នាក់ គ្មានបានធ្វើអីគេទេ

ក៖ អូ៎!បាទមីងបាទ?

ខ៖ យើងគ្មានធ្វើអីទេគ្រាន់តែយើងអ៊ុំអង្ករ ដាំបាយចឹងទៅ
ហើយប្ដីលីស្រូវទៅកិនអោយស៊ីចឹងទៅ រួចគេទៅចងកណ្ដាប់អីចឹងទៅ

ក៖ អូ៎!ចុះមីង?

ខ៖ គេមិនដែរអោយខ្ញុំពិបាកទេ ប៉ុន្តែមកពីខ្ញុំទាស់ឆ្លងទន្លេនឹង អាំងភ្លើងវាមិនដល់
ផឹកស្រាវាមិនកើត បានវាស្គមស្វិតចឹងហាស

ក៖ ចុះមីងគិតថាមីងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរមីង?

ខ៖ ចាំ!ថាម៉េច?

ក៖ ដូចជាមីងឆ្លងកាត់ការលំបាកមួយនឹង ដូចជាពុះពារឧបសគ្គមួយនឹងយ៉ាងម៉េចដែរមីង
លក្ខណៈជំនះវាចឹងហាសមីង

ខ៖ គេមិនដែរប្រើខ្ញុំទេនឹងកាលនៅជាមួយហោស គេទៅគាស់រើសរាំងអីនឹង
ទៅស៊ីឈ្នួលរើសរាំងគេមក អោយហើយទិញក្រវិល ទិញចញ្ចៀនអីមកពាក់ចឹងទៅណាស់

ក៖ ចឹងហោសមីង?

ខ៖ រួចនឹងទៅធ្វើការនៅស្ពានអីហោសដល់ពេលចឹងបានមួយជីយកមកអោយនឹង
អោយកូនស៊ីទៅរហូត នឹងទាល់តែកូននឹងធំទៅណាស់

ក៖ អូ៎!ល្អដែរហោសមីង?

ខ៖ ប្តីរបស់ខ្ញុំមិនដែររករឿងខ្ញុំទេ តែខ្ញុំនឹងមករអ៊ូច្រើនឹងហោសគេរល់តែរត់ទៅម៉ែគេវិញហោស

ក៖ មីងខ្លាំងដែរចឹង?

ខ៖ ហីអត់បានទេម៉ែគេនៅស្រុកផ្តៅនៅណោះ

ក៖ ប្តីរបស់មីងហោសមីង?

ខ៖ ចា៎!នឹងហើយប្តីរបស់ខ្ញុំនឹងជិតហាស ខ្ញុំដើរទៅផ្ទះម៉ែក្មេករបស់ខ្ញុំនឹងរាល់តែដងនឹង

ក៖ ទៅយកគាត់មកវិញ?

ខ៖ ជូនណាជិះកងគ្មានទៅយកទេនៅណុងគេមកមកគេមិនមកហីទៅ

ក៖ ឥឡូវនឹងគាត់នៅណុង?

ខ៖ នៅផ្ទះម៉ែរបស់ខ្ញុំនឹង

ក៖ ប៉ុន្តែមីងមិនបានឈ្លោះគ្នាអីទេ?

ខ៖ អត់មានឈ្លោះគ្នាអីទេនឹង

ក៖ ចុះមីងគិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់មីងដែរទៅ?

ខ៖ ខ្ញុំមិនដែរសប្បាយចិត្តទេពេលមានប្តីមានកូននឹង កូនរលួយដូចដង្កូវប្រេហុកនឹងគ្មានបានដើរទៅណា ទេនឹង

ក៖ ចុះមីងកាលពីក្មេងនឹងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងមីងចង់ធ្វើអីទេ?

ខ៖ ថាម៉េច?

ក៖ មីងកាលពីក្មេងហាតើមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងមីងចង់ធ្វើអីទេ?

ខ៖ អត់មាន

កៈ លក្ខណៈថាពេលដែរមីងនៅរៀនចឹងហាស លក្ខណៈថាមីងចង់ធ្វើជាគ្រូបង្រៀនរឺមួយធ្វើគ្រូពេទ្យអី?

ខៈ
អត់មានទេគិតថាអោយតែរៀនបានមើលអក្សរចេះតិចៗអាចមើលដាច់ទៅបានហើយនឹង

កៈ អូ!ចឹងហោសមីង
ចុះបើសិនជាចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗតើមីងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរមីង?

ខៈ
ផ្ដែផ្ដាំថាអោយយើងចេះតែរៀនសូត្រទៅអោយបានចេះដឹងកុំអោយវាល្ងង់ល្ងឺតវាភ្លើទៅណាស់រកស៊ុីអីនឹងក៏គេមិនអាចបំបាត់យើងបានដែរនឹង

កៈ
ចុះបើសិនជាចង់អោយគាត់ជៀសវៀងវិញតើមីងចង់អោយគាត់ជៀសវៀងអីគេដែរមីង?

ខៈ ជៀសវៀងល្បែង ជៀសវៀងអារឿងថ្នាំញៀនអីនឹងអានឹងមិនកើតទេ
មិនកើតជាមនុស្សទេនឹង

កៈ ចឹងមានអីចង់ផ្ដែផ្ដាំអីផ្សេងទៀតទេមីង?

ខៈ ផ្ដែផ្ដាំកូនតែប៉ុណ្ណឹងថាល្បែងកុំលេង ថ្នាំញៀនអីកុំកាន់កុំពាល់របស់នេះខុសច្បាប់

កៈ បាទត្រូវហើយមីង?

ខៈ គេចាប់ គេចង គេដាក់គុកដាក់ច្រវាក់ខ្ញុំប្រដៅតែប៉ុណ្ណឹង

កៈ ចឹងអត់មានអីដែរចង់ប្រាប់ពួកគាត់ថា
ពេលដែរពួកគាត់ធំឡើងនឹងពួកគាត់ចង់ធ្វើអីផ្សេងទៀតទេណា មីង?

ខៈ អត់ខ្ញុំថាតាមគំនូកំនត់ទៅតាមវាសនាកូនទៅចុះណាស់
បើកូនរៀនមិនចេះតាមប្រាជ្ញាវាទេធ្វើតែតាម កំលាំងវាទៅណាស់
ធ្វើតែស្រែចំការដដែរចឹងទៅពីព្រោះយើងគ្មានពូជវង្សត្រកូលណាបាន ទៅធ្វើរាជការនឹងគេណាទេណាស់

កៈ  បាទមីងបាទ?

ខៈ  គ្មានបានទៅធ្វើរដ្ឋមន្រ្តីណាទេ បើស្រែចំការនឹងស្រែចំការទៅហើយនឹងខ្ញុំគិតចឹងតើ

កៈ  បាទមីងបាទ?

ខៈ  ខ្ញុំគិតចឹងនឹង

កៈ  ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង
នឹងមីងបានផ្តល់ពេលវេលាបានមកជួបខ្ញុំចឹងហាសមីង
បាទអរគុណច្រើនណាស់មីង៕៕៕